មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## ២- សេចក្តីសំរេច

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៨ ខែ វិច្ឆិកា ឆ្នាំ ២០០០

### សេចក្តីសំរេច លេខ ៦៤ សសរ
### ស្តីពី
### ការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីតាមដាន និង បង្ក្រាបក្រុមភេរវកម្មប្រដាប់អាវុធ

* * *

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/០២/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសភាពការណ៍ចាំបាច់ របស់រាជរដ្ឋាភិបាល

### សំរេច

ប្រការ ១ .- បង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីតាមដាន និងបង្ក្រាបក្រុមភេរវកម្មប្រដាប់អាវុធ ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម ស ខេង | ឧបនាយករដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម យូ ហុកគ្រី | សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣-ឯកឧត្តម ទៀ បាញ់ | សហរដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| ៤-ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ស៊ីរីរ័ត្ន | សហរដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |

៥-ឯកឧត្តម កែ គឹមយ៉ាន អគ្គមេបញ្ជាការរង [illegible]ខេមរភូមិន្ទ សមាជិក

៦-ឯកឧត្តម ហុក ឡុងឌី អគ្គនាយកនគរបាលជាតិ សមាជិក

៧-ឯកឧត្តម ខ្ទិម យ៉ិនឡៀង ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី សមាជិក

៨-ឯកឧត្តម អន្ទ ខន្សុខម្សានា រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក

៩-ឯកឧត្តម ពេជ្រ ម៉ិនធិន រដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សមាជិក

១០-ឯកឧត្តម ឡុង វិសាលោ អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១១-ឯកឧត្តម ឧត្តមសេនីយ៍ឯក មាស សុភា អគ្គមេបញ្ជាការរង កងយោធពលខេមរភូមិន្ទ សមាជិក

១២-ឯកឧត្តម ឧត្តមសេនីយ៍ឯក មល់ ឡើម ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី សមាជិក

១៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

១៤-ឯកឧត្តម ឧត្តមសេនីយ៍ទោ យូ ស៊ិនឡុង ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី សមាជិក

១៥-ឯកឧត្តម ឧត្តមសេនីយ៍ទោ នេត្រ សាវឿន ប្រធាននាយកដ្ឋានកណ្តាលយុត្តិធម៌ក្រសួងមហាផ្ទៃ សមាជិក

១៦-ឯកឧត្តម ណាំ នុំ ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី សមាជិក

១៧-លោកឧត្តមសេនីយ៍ត្រី ជុំ ហាក់ ប្រធានការិយាល័យទី២ កងទ័ពជើងគោក សមាជិក

១៨-លោកឧត្តមសេនីយ៍ត្រី សុខ ផល ប្រធាននាយកដ្ឋានពត៌មានទូទៅក្រសួងមហាផ្ទៃ សមាជិក

១៩-លោកឧត្តមសេនីយ៍ត្រី គន្ធ សំអឿន ប្រធាននាយកដ្ឋានភេរវកម្មក្រសួងមហាផ្ទៃ សមាជិក

ប្រការ ២ : គណៈកម្មការចំរុះអន្តរក្រសួងនេះ មានភារកិច្ចដូចតទៅ :

-ស្រាវជ្រាវត្រួតពិនិត្យ និងតាមដានអោយបានច្បាស់លាស់នូវរាល់សកម្មភាពភេរវកម្មប្រដាប់អាវុធ ដែលបង្កឡើងដោយក្រុមជនមួយចំនួន ដើម្បីបំផ្លិចបំផ្លាញសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសុវត្ថិភាពសង្គម ។

-លើកវិធានការទប់ស្កាត់ និងបង្ក្រាបអោយមានប្រសិទ្ធភាពតាមផ្លូវច្បាប់ ។

-លើកសំណើជូនរាជរដ្ឋាភិបាលសុំផ្អាកការងារបណ្តោះអាសន្ន មន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈយោធិន កងរាជអាវុធហត្ថ និងនគរបាល ដែលពិនិត្យឃើញមានការពាក់ព័ន្ធជាមួយ

និងអំពើភេរវកម្មប្រដាប់អាវុធ ដើម្បីងាយស្រួលក្នុងការធ្វើការស្រាវជ្រាវ និងចាត់ការបន្តតាមនីតិច្បាប់ ។

-ធ្វើសហប្រតិបត្តិការចរចា និងសំរបសំរួលជាមួយបណ្តាប្រទេស ដែលពួកភេរវកម្មប្រដាប់អាវុធបាននឹងកំពុងស្នាក់នៅ ដើម្បីចាត់បញ្ជូនតាមផ្លូវច្បាប់ប្រគល់មកអោយអាជ្ញាធរមានសមត្ថកិច្ចកម្ពុជាដោះស្រាយ ឬចាត់ការកាត់ទោសតាមផ្លូវច្បាប់ នៃប្រទេសដែលពោលខាងលើ ។

-ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល អំពីលទ្ធផលការងារដែលអនុវត្ត និងសុំយោបល់សំរេចក្នុងករណីចាំបាច់ ។

ប្រការ ៣ : គណៈកម្មការចំរុះអន្តរក្រសួង មានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយតាមការចាំបាច់ ដើម្បីជាជំនួយការ ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងសមាសភាពចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
ហ៊ុន សែន

★★★